# សិល្បៈគំនូររឿងរាមកេរ្តិ៍នៅតាមវត្ត (ភាគ២)

នៅក្នុងអត្ថបទភាគ១ ខ្ញុំបាននិយាយរួចមកហើយអំពីគំនូររឿងរាមកេរ្តិ៍នៅថែវព្រះវិហារព្រះកែវមរកត ក្នុងព្រះបរមរាជវាំង ព្រះវិហារវត្តរាជបូព៌ ក្នុងក្រុងសៀមរាប និងព្រះវិហារវត្តកំពង់ត្រឡាចលើ ស្ថិតក្នុងស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង។ គំនូរទាំងអស់នោះសុទ្ធសឹងជាគំនូរបុរាណ ដែលសាងឡើងរវាងចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០។ ក្នុងអត្ថបទនេះ ខ្ញុំសូមបង្ហាញជូនគំនូររឿងរាមកេរ្តិ៍នៅតាមវត្តមួយចំនួនទៀត ដែលសាងឡើងចុងសតវត្សរ៍ទី២០ ឬឆ្លងមកដល់ក្នុងសម័យទំនើបថ្មី។

## ៤. ព្រះវិហារវត្តទន្ទាប់

វត្តទន្ទាប់ ឬវត្តទន្ទាប់រង្សី ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ តាមការសិក្សារបស់ Daniel Guéret និង Dominique-Pierre Guéret យល់ថាព្រះវិហារវត្តនេះកសាងក្នុងឆ្នាំ១៩២៨។[1] បើផ្អែកតាមសំណេរចារនៅលើជញ្ជាំងថា "កសាងពីឆ្នាំឆ្លូវ កាលពុទ្ធសករាជ២៤៩២" ដែលកាលបរិច្ឆេទនេះត្រូវនឹងរវាងឆ្នាំ១៩៤៩ ឯជាងគំនូរឈ្មោះ "ផរ"។ កាលបរិច្ឆេទនេះប្រហែលកត់ត្រាឆ្នាំសាងគំនូរ។ ប៉ុន្តែទោះយ៉ាងណាក្តីវិហារវត្តនេះជាស្ថាបត្យកម្មដ៏ចំណាស់មួយក្នុងនិគមជនបទ ដែលសេសសល់ពីសង្គ្រាម ហើយត្រូវបានជួសជុលថែរក្សាយ៉ាងគត់ម៉ត់គង់វង្សដល់សព្វថ្ងៃ។ ចំពោះគំនូរពាក់ព័ន្ធនឹងរឿងរាមកេរ្តិ៍ គេឃើញមានតែត្រង់អន្ទើខ្ចី។ ឬតួអង្គសំខាន់ៗនៅលើជញ្ជាំងខាងក្រៅព្រះវិហារតែប៉ុណ្ណោះ (រូបលេខ១-២)។




រូបលេខ១-២ ព្រះវិហារវត្តទន្ទាប់ក្រោយជួសជុលរួចរាល់ជាស្ថាពរ

[1] Daniel Guéret & Dominique-Pierre Guéret 2017: 147

អត្ថបទដោយៈ ហឿន សុវណ្ណមរកត

គំនូរលើជញ្ជាំងខាងកើត ប្រហែលលោកគូរឆាកប្រយុទ្ធគ្នារវាងព្រះលក្ស្មណ៍ និងឥន្ទ្រជិតនៅក្នុងផ្ទាំងធំមួយ ដែលមានពលស្វានិងពលយក្សគាំទ្រជុំវិញរៀងខ្លួន ដ្បិតពុំមានចំណារបញ្ជាក់ផង(រូបលេខ៣)។ រីឯគំនូរលើជញ្ជាំងខាងលិច ជាឆាកប្រយុទ្ធដណ្ដើមនាងសីតារវាងអង្គទ និងក្រុងរាពណ៍(?)[2] ហើយនៅអមឆាកប្រយុទ្ធនេះ លោកគូរម្ខាងជាតួអង្គផៃណាសូរវង្សជាសេនាក្រុងរាពណ៍ និងម្ខាងទៀតលោកគូរនិលឯកជាសេនាព្រះរាម (រូបលេខ៤-៦)។ ចំណែកនៅលើជញ្ជាំងចំហៀងខាងជើង និងខាងត្បូង លោកគូរចម្រុះសាច់រឿងក្នុងពុទ្ធប្រវត្តិផង និងអន្ទើខ្លះៗក្នុងរឿងរាមកេរ្តិ៍ផងដូចជា ហនុមានសម្ដែងឫទ្ធិ កុម្ភការណ៍សម្ដែងឫទ្ធិ និងសុគ្រីពដករាំងកាលក្នុងឧទ្យានក្រុងលង្ការជាដើម។



រូបលេខ៣-៦ គំនូរព្រះលក្ស្មណ៍ប្រយុទ្ធនឹងឥន្ទ្រជិត អង្គទដណ្ដើមព្រះនាងសីតា ស្រុគីពដកដើមរាំងកាល និងពលស្វា-យក្សសម្ដែងឫទ្ធិ

[2] ជាធម្មតាតួអង្គក្រុងរាពណ៍មានមុខ១០ (ទសមុខ) ហើយក្នុងគំនូរច្រើនគូរដៃ៤ ឬ៨ ឬ១០ ឬ២០។ ប៉ុន្តែក្នុងរូបនេះគឺជាយក្សដែលមានដៃ២ មុខ១ តែសំណេរបញ្ជាក់ក្បែរនោះថាជាស្ដេចរាពណ៍។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ៩. ព្រះវិហារវត្តអង្គរខាងជើង

ក្នុងបរិវេណកំពែងប្រាសាទអង្គរវត្ត មានវត្តព្រះពុទ្ធសាសនាពីរ គឺវត្តមួយស្ថិតនៅខាងជើង និងវត្តមួយទៀតស្ថិតនៅខាងត្បូង។ វត្តស្ថិតនៅទិសខាងជើងហៅថាវត្តអង្គរខាងជើង ឬវត្តឥន្ទបត្តបុរី(រូបលេខ៧-៨)។ ព្រះវិហារវត្តនេះ ប្រហែលរុះរើចេញពីក្បែរខឿនប្រាសាទអង្គរវត្តមកសាងជាថ្មីលើទីតាំងបច្ចុប្បន្នក្នុងដើមទសវត្សរ៍ទី៦០ ហើយបច្ចុប្បន្នគេឃើញមានគំនូរពណ៌រឿងរាមកេរ្តិ៍លើជញ្ជាំងខាងក្រៅព្រះវិហារ គូរបង្ហាញអន្ទើខ្លីៗប៉ុន្មានផ្ទាំង។ គំនូរទាំងនោះ គូរនៅក្នុងរវាងពាក់កណ្តាលទសវត្សរ៍ទី៩០ ដោយវិចិត្រករ ប៊ូ ម៉េង[3] និង ណៃម សុភី។



រូបលេខ៧-៨ ព្រះវិហារវត្តអង្គរខាងជើងថតឆ្នាំ១៩៦៨ (រូប៖ G. Condominas) និងរូបថតឆ្នាំ២០២១

ចំពោះអន្ទើដែលវិចិត្រករទាំងពីរខាងលើស្រង់មកគូរយ៉ាងសង្ខេបមានដូចជា ព្រះរាមប្រឡងធ្នូនិងរៀបអភិសេកនៅនគរមិថិឡា ព្រះរាម ព្រះលក្ស្មណ៍ និងព្រះនាងសីតាចេញពីព្រះនគរទៅអាស្រមឥសីក្នុងព្រៃ ព្រះរាម និងព្រះលក្ស្មណ៍សម្លាប់យក្សឈ្មោះកាកនាសូរ ព្រះរាមបាញ់ប្រើសមាសឈ្មោះមហារីក ក្រុងរាពណ៍ឆក់ព្រះនាងសីតា រហូតដល់ត្រួសៗដល់ហនុមានស្វែងរកព្រះនាងសីតា ហនុមានបំផ្លាញក្រុងលង្កា ព្រះរាមផ្លែងសរសម្លាប់រាពណ៍ និងវិលចូលព្រះនគរជាដើម (រូបលេខ៩-១២)។

[3] វិចិត្រករ ប៊ូ ម៉េង ធ្លាប់មានស្នាដៃគូរជួសជុលគំនូរក្នុងព្រះវិហារវត្តព្រះស៊ីសុវត្ថិរតនារាម ខេត្តកណ្តាល

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩-១២ គំនូររឿងរាមកេរ្តិ៍នៅជញ្ជាំងខាងក្រៅនៃព្រះវិហារវត្តអង្គរខាងជើង

## ៦. ព្រះវិហារវត្តឫស្សីជ្រោយ

វត្តឫស្សីជ្រោយ ឬវត្តមហាអម្ពវ័ន ស្ថិតនៅក្នុងឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្ដាល ដែលមានព្រះវិហារកសាងតាំងពីចុងទសវត្សទី៤០ (រូបលេខ១៣)។ គំនូរពាក់ព័ន្ធរឿងរាមកេរ្តិ៍ក្នុងព្រះវិហារនេះ គូរលើពិតានឈើនៅចំពីលើរបៀងសងខាង ដែលអមល្វែងគ្រឹះ។ គំនូរនីយមួយៗមានសាច់រឿងជាផ្ទាំងខណ្ឌដោយស៊ុមក្បាច់ដូចជា ព្រះរាមប្រយុទ្ធជាមួយក្រុងរាពណ៍ ពាលីប្រយុទ្ធជាមួយក្របីទូភី ពាលីប្រយុទ្ធជាមួយសុគ្រីព ក្រុងរាពណ៍ឆក់នាងសីតា ព្រះលក្ស្មណ៍ប្រយុទ្ធជាមួយយក្ស ហនុមានប្រយុទ្ធជាមួយយក្ស ហនុមានចាប់នាងសុវណ្ណមច្ឆា និងហនុមានចាប់នាងបុញ្ញកាយ (រូបលេខ១៤-២១)។ រីឯគំនូរនៅត្រង់ចន្លោះល្វែងគ្រឹះ វិចិត្រករគូរអន្ទើខ្លះក្នុងរឿងពុទ្ធប្រវត្តិ និងវង់ព្រះអាទិត្យ-ព្រះច័ន្ទ្រ តែបញ្ចូលតួអង្គនាងមេខលា និងរាមឥសូរ អមព្រះអាទិត្យទឹមគោ (រូបលេខ២២) ហើយនាងមន្ទោគិរី និងហនុមាន អមព្រះច័ន្ទ្រទឹមទន្សាយ (រូបលេខ២៣)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ១៣-១៥ ព្រះវិហារវត្តឫស្សីជ្រោយ និងគំនូរព្រះរាមប្រយុទ្ធជាមួយក្រុងរាពណ៍





រូបលេខ១៦-១៨ ពាលីប្រយុទ្ធជាមួយទូភី, ពាលីប្រយុទ្ធជាមួយស្រុគីព, ក្រុងរាពណ៍ឆក់នាងសីតា





រូបលេខ១៩-២១ ព្រះលក្ស្មណ៍ប្រយុទ្ធជាមួយវៃដាល, ហនុមានចាប់នាងមច្ឆា, ហនុមានចាប់នាងបុញ្ញកាយ



រូបលេខ២២ ព្រះអាទិត្យនិងមេខលា-រាមឥសូរ



រូបលេខ២៣ ព្រះចន្ទ្រនិងនាងមន្ទោគិរី-ហនុមាន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ៧. ព្រះវិហារវត្តតាំងក្រសាំង

វត្តតាំងក្រសាំង ឬវត្តរតនារាម ស្ថិតក្នុងឃុំក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។ ព្រះវិហារវត្តនេះ ជាសំណង់ថ្មីសម័យក្រោយ តែគំនូរផ្នែកខាងក្នុងមានបញ្ចូលសាច់រឿងរាមកេរ្តិ៍ដោយអន្ទើៗសរុបប្រហែល២០ផ្ទាំង។ គំនូរទាំងនោះជាគំនូរពណ៌ដូចបណ្តាគំនូរពុទ្ធប្រវត្តិដទៃ ហើយគំនូរក្នុងព្រះវិហារនេះជាស្នាដៃវិចិត្រករពីររូបឈ្មោះ កង ផុន និង ម៉ឹង ដាម។ លើជញ្ជាំងជុំវិញ គំនូររឿងរាមកេរ្តិ៍គូរនៅជួរខាងក្រោមបំផុត ជួរលើបំផុតគូររឿងពុទ្ធប្រវត្តិ និងជួរកណ្តាលគូររឿងជាតក តែនៅលើពិតានក៏មានគំនូររឿងរាមកេរ្តិ៍មួយផ្ទាំងធំដែរ (រូបលេខ២៤-២៥)។




*រូបលេខ២៤-២៥ ព្រះវិហារវត្តតាំងក្រសាំង និងគំនូរខាងក្នុងព្រះវិហារ*

ចំពោះខ្លឹមសារគំនូររឿងរាមកេរ្តិ៍ក្នុងព្រះវិហារវត្តតាំងក្រសាំង ហាក់សង្ខេបខ្លីបំផុត ចាប់ផ្តើមពីអន្ទើត្រង់ព្រះរាមរៀបអភិសេកជាមួយព្រះនាងសីតា ដែលវិចិត្រករកំណត់ជាអន្ទើទី១ (រូបលេខ២៦) ហើយគំនូរជាបន្តបន្ទាប់មក រៀបរាប់ពីដំណើរជីវិតព្រះរាមព្រះលក្ស្មណ៍តាំងពីចេញពីព្រះនគរដូចជា ព្រះរាមព្រះលក្ស្មណ៍សុំពរពីឥសី សម្លាប់យក្សជួបគ្រុឌ ជ្រកក្រោមម្លប់ស្វាយ ព្រះនាងសីតាជួបឥសី ចម្បាំងនៅនគរលង្ការ ព្រះរាមបញ្ជាព្រះលក្ស្មណ៍សម្លាប់ព្រះនាងសីតា រហូតដល់អន្ទើត្រង់ព្រះរាមចូលកោដ្ឋបញ្ជោទព្រះនាងសីតាជាអន្ទើចុងបញ្ចប់ (រូបលេខ២៧)។

រីឯគំនូរពាក់ព័ន្ធនឹងរឿងរាមកេរ្តិ៍មួយផ្ទាំងនៅលើពិតាន វិចិត្រករគ្រាន់តែគូររូបតួអង្គមួយចំនួនលាយចម្រុះនឹងតួអង្គផ្សេងទៀតដូចជាយក្ស ទេវតា និងតាពនិករនានា។ តួអង្គសំខាន់នោះគឺ ក្រុងរាពណ៍ឆក់នាងសីតា និងគ្រុឌឆក់នាងកាកី (រូបលេខ២៨)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត







រូបលេខ២៦-២៨ គំនូរផ្ដើម និងបញ្ចប់សាច់រឿងរាមកេរ្តិ៍លើជញ្ជាំង និងពិតានព្រះវិហារវត្តតាំងក្រសាំង

ជារួមមក គំនូររឿងរាមកេរ្តិ៍នៅក្នុងវត្តចំនួន៤ផ្សេងទៀតនៃអត្ថបទភាគ២នេះ គឺជាគំនូរពណ៌ធម្មតា មិនដូចគំនូរតាមព្រះវិហារបុរាណឡើយ។ ជាទូទៅខ្លឹមសាររឿងខ្លីៗមិនលម្អិតដូចគំនូរបុរាណក្នុងអត្ថបទភាគ១។ ប៉ុន្តែយ៉ាងណាក្តី ការនិយមគូរគំនូររឿងរាមកេរ្តិ៍ក្នុងព្រះវិហារបែបនេះ អ្នកស្រុកខ្លះចាត់ទុកព្រះរាមក៏ជាព្រះពោធិសត្វដែរ។[4]

[4] សាន ផល្លា, ២០០៧: ១៥៣-១៥៩

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

# ឯកសារយោង

កក់ ច័ន្ទ ថាត

១៩៩៦, *គំនូរបុរាណរឿងរាមកេរ្តិ៍នៅថែវព្រះវិហារព្រះកែវមរកត (ព្រះបរមរាជវាំង)*, មូលនិធិតូយូតា, ភ្នំពេញ

សាគូ សាមុត

២០០៧, *រឿងរាមកេរ្តិ៍*, បណ្ណាគារអង្គរ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រៃយំ, ភ្នំពេញ

Danielle & Dominique-Pierre Guéret

2017, *The Khmer Pagoda*, KAM édition

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត